ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៨៧៣

ចុះថ្ងៃទី ០៥-០៩-២០១៦

សាលដីកា

លេខ ៣៦ ក្រ॥ ·ល·

ចុះថ្ងៃទី ២៤-០៥-២០១៧

# តាមនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៤ ។

បានបើកសវនាការជាសាធារណៈ នាសាលសវនាការនៃសាលាឧទ្ធរណ៍នៅថ្ងៃទី២៧ ខែ មេសា ឆ្នាំ២០១៧ ដោយមានសមាសភាពដូចខាងក្រោម៖

## សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

ឯកឧត្តម [redacted] ជាចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

## ក្រឡាបញ្ជីសវនាការ

កញ្ញា [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍សំណុំរឿងព្រហ្មទណ្ឌលេខ ៨៧៣ ចុះថ្ងៃទី០៥-០៩-២០១៦ ដែលមាន៖

-ជនជាប់ចោទឈ្មោ[redacted]ភេទប្រុស អាយុ ២១ឆ្នាំ ជនជាតិខ្មែរ មុខរបរ ដើររើសអេតចាយ ទីកន្លែងកំណើតស្រុកពាមរ៍ ខេត្តព្រៃវែង ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល សង្កាត់ច្បារអំពៅ២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ[redacted] ប្រពន្ធឈ្មោះ[redacted]មានកូន ០៣នាក់ ជាទិតជន ទៅសពីមុនគ្មាន។ (ដីកាឃុំខ្លួនលេខ ៣៤២៤ តព្រ ចុះថ្ងៃទី១០.១២.២០១៥ មទ)

មានលោក [redacted]ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

<u>ជាប់ចោទពីបទ:</u> លួចកេខស្ពានមួយទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៥Z ផ្លូវលេខ៣៧៦ ក្រុម៥១ ភូមិ០១ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

បណ្តឹងឧទ្ធរណ៍លេខ ៥៤៥ ចុះថ្ងៃទី ១៥-០៨-២០១៦ របស់ជនជាប់ចោទឈ្មោះ[redacted]ប្តឹងឧទ្ធរណ៍ជំទាស់សាលក្រមព្រហ្មទណ្ឌលេខ ២៩៥ ក្រ៥ "ធ" ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានី



Scanned by CamScanner

ភ្នំពេញ គ្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

## ៦រឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ២០១៥ វេលាម៉ោងប្រហែលបីយប់ ជនរងគ្រោ[redacted]និងបានជិះម៉ូតូ០១ គ្រឿងម៉ាក ស្កុបពី ពណ៌ស លាយលឿងខ្ចី ស៊េរី ២០១២ ពាក់ស្លាកលេខ ភ្នំពេញ 1BJ-6449 មកពីជួបមិត្តភក្តិ ពេលជិះម៉ូតូដល់ផ្ទះបានទុកម៉ូតូនៅក្នុងផ្ទះ ស្ថិតនៅលេខ ៥៥Z ផ្លូវលេខ ៣៧៦ ក្រុម៥១ ភូមិ០១ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយពុំបានដកកូនសោរចេញពីម៉ូតូទេ រួចចាក់សោរទ្វារផ្ទះត្រឹមត្រូវ ហើយក៏ទៅដេកនៅលើផ្ទះជាន់ទី១ រហូតដល់ម៉ោងប្រហែល ០៧ និង០០នាទីព្រឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ខ្លួនភ្ញាក់ពីដំណេកចុះមកក្រោមឃើញទ្វារចំហរ និងមានស្នាមគាស់បង្ខូចហើយបាត់ពុំឃើញម៉ូតូមិនដឹងចោរលួចតាំងពីពេលណាមកទេ។ បន្ទាប់មកជនរងគ្រោះក៏បានដាក់ពាក្យបណ្តឹងមកប៉ុស្តិ៍នគរបាលសង្កាត់បឹងកេងកង៣ វេលាម៉ោង ១៩ និង៣០នាទី នាថ្ងៃខែឆ្នាំដដែលសមត្ថកិច្ចបានធ្វើការឃាត់ខ្លួនជនសង្ស័យឈ្មោ[redacted]ភេទប្រុស អាយុ ២១ ឆ្នាំ និងបានធ្វើការដកហូតវត្ថុតាងមាន ម៉ូតូមួយគ្រឿងម៉ាក ស្កុបពី ពណ៌សលាយលឿងខ្ចី គ្មានស្លាកលេខ លេខតួ លេខម៉ាស៊ីន 046064។

-បានឃើញ ចម្លើយរបស់ជនរងគ្រោះឈ្មោ[redacted]ានឆ្លើយនៅថា កាលពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៥ ប្រហែលម៉ោង ២៤ និង០០នាទី ខ្លួន និងប្តីបានជិះម៉ូតូ ០១គ្រឿងម៉ាកស្កូពីពណ៌ស លាយលឿងខ្ចីឆ្នាំ២០១២ ពាក់ស្លាកលេខភ្នំពេញ 1BJ-6449 លេខតួ និងលេខម៉ាស៊ីនលេខ ០៤៦០៦៤ មកពីជួបជុំមិត្តភ្តិ ពេលដល់ផ្ទះបានទុកម៉ូតូនៅខាងក្នុងផ្ទះ ពុំបានដកកូនសោរចេញពីម៉ូតូទេ រួចចាក់សោរផ្ទះត្រឹមត្រូវ ហើយក៏ឡើងដេកនៅជាន់ទី១ រហូតដល់ម៉ោងប្រហែល ០៧ និង០០នាទីព្រឹក ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៥ ខ្លួនភ្ញាក់ពីដេកចុះមកក្រោមឃើញទ្វារចំហរ និងមានស្នាមគាស់បង្ខូចហើយបាត់ម៉ូតូមិនដឹងចោរចូលលួចតាំងពីពេលណាមកទេ។

*បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៩៥ ក្រ៥ "ធ" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារដូចខាងក្រោម៖*

១-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ារ៉ូន ភេទប្រុស អាយុ ២១ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ (បី)ឆ្នាំ ពីបទ៖ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចផ្ទះលេខ៥៥Z ផ្លូវលេខ ៣៧៦ ក្រុមទី៥១ ភូមិ០១ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃ០៧ ខែធ្នូ ឆ្នាំ២០១៥ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២-វត្ថុតាប់យកមាន៖ ទូរស័ព្ទម៉ាកសាំងសុង ពណ៌ខ្មៅ ចំនួន ០១គ្រឿង ដែលមិនមែនជាវត្ថុតាងក្នុងការប្រព្រឹត្តបទល្មើស សម្រេចប្រគល់ឲ្យម្ចាស់ដើមវិញ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២២ ខែកក្កដា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌ ចុះថ្ងៃទី ០២-០១-២០១៧ របស់សាលាឧទ្ធរណ៍ ។

បានឃើញ សេចក្តីសន្និដ្ឋាន ចុះថ្ងៃទី ១៨-០៤-២០១៧ របស់មហាអយ្យការអមសាលាឧទ្ធរណ៍។



Scanned by CamScanner

បានឃើញ ដីកាចាត់តាំងសមាសភាពក្រុមប្រឹក្សាជំនុំជម្រះទី២លេខ ២០ ដក២០១៧ ចុះថ្ងៃទី ០២-០៣-២០១៧។

<u>**នាពេលសវនាការ**</u>

-ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបរឿង

-ជនជាប់ចោទឈ្មោ[redacted]ានឆ្លើយថា ខ្លួនព្រមទទួលយកលោក[redacted]ជាមេធាវីការពារសិទ្ធិឲ្យខ្លួន។ ខ្លួនប្តឹងឧទ្ធរណ៍នេះដើម្បីសុំឲ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសឲ្យខ្លួន ដើម្បីឲ្យខ្លួនបានកែប្រែខ្លួនក្លាយជាពលរដ្ឋល្អវិញ។ ខ្លួនមិនបានកាប់គាស់ទម្លុះទម្លាយទេ គឺខ្លួនបានបើកបង្អួចរួចចូលទៅក្នុងផ្ទះហើយក៏បើកទ្វារពីខាងក្នុងនិងបានយកម៉ូតូចេញ រួចក៏ជិះយកទៅផ្ញើរនៅពេទ្យក្បាលថ្នល់រួចក៏ទៅដេក លុះព្រឹកឡើងក៏មកយកម៉ូតូដែលផ្ញើរជិះចេញមកក៏រស់សាំងហើយក៏ត្រូវប៉ូលីសឃាត់ខ្លួនតែម្តង។ ខ្លួនមិនដឹងថាម៉ូតូនេះមានផ្លាកលេខ ឬក៏អត់នោះទេ។ សូមឲ្យក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់ខ្លួនផង។

តំណាងមហាអយ្យការសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឃើញថាធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់យោងមាត្រា ៣៧៥ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជនជាប់ចោទបានសារភាពជនជាប់ចោទប្តឹងឧទ្ធរណ៍ទឹងចំណុចទាំងមូលតែពេលនេះបានបង្ហាញឆន្ទៈគ្រាន់តែសុំបន្ធូរបន្ថយទោស តែកាលដែលសាលាដំបូងសម្រេចផ្តន្ទាទោសនេះឃើញថាស្ថិតនៅក្នុងកម្រិតអប្បរមាហើយ សូមក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។

-លោក[redacted]ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទសន្និដ្ឋានថា ក្រោយពីពិភាក្សាដេញដោលឃើញថាកូនក្តីខ្លួនបានសារភាពថាខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ដោយឥតលាក់លៀម។ ជាងនេះទៅទៀតកូនក្តីខ្លួនមិនបានកាប់គាស់ទម្លុះទម្លាយទេ គឺកូនក្តីខ្លួនគ្រាន់តែបានរុញបង្អួចរួចក៏ចូលទៅបើកទ្វារពីខាងក្នុងរួចក៏បណ្តើរម៉ូតូចេញ។ សូមក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនតាមមាត្រា ៩៣ នៃក្រមព្រហ្មទណ្ឌ។

*ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ*

*ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ*

*ក្រោយពីបានពិចារណាលើគ្រប់ឯកសារ និងភស្តុតាងផ្សេងៗ*

*ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ*

<u>**សាលាឧទ្ធរណ៍**</u>

<u>**យល់ឃើញថា**</u>

១-បណ្តឹងឧទ្ធរណ៍លេខ៥៤៥ ចុះថ្ងៃទី១៥-០៨-២០១៥ របស់ជនជាប់ចោទឈ្មោ[redacted]ប្តឹងឧទ្ធរណ៍ និង



Scanned by CamScanner

សាលក្រមព្រហ្មទណ្ឌលេខ ២៩៥ ក្រ៥ "ធ" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូល នៃសេចក្តីសម្រេច បណ្តឹងនេះធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះយកមកជំនុំជម្រះបាន យោងតាមមាត្រា ៣៧៦ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ប៉ុន្តែខ្លួនមិនបានកាប់គាស់ទម្លុះទម្លាយទេ តែនៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ជនជាប់ចោទដដែលនេះបានឆ្លើយបញ្ជាក់ថា ខ្លួនបានធ្វើសកម្មភាពគាស់ទ្វារបង្អួចចូលទៅក្នុងផ្ទះ រួចបើកទ្វារផ្ទះខាងមុខ បន្ទាប់មកខ្លួនបានលួចយកម៉ូតូ ។ ម្យ៉ាងវិញទៀត តាមចម្លើយរបស់ជនរងគ្រោះ និងភស្តុតាងនានាក្នុងសំណុំរឿង ស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ដែលអាចបញ្ជាក់បានថាជនជាប់ចោទឈ្មោះ [redacted] ពិតជាបានកាប់គាស់ទម្លុះទម្លាយដើម្បីលួចយកម៉ូតូប្រាកដមែន។ អំពើរបស់ជនជាប់ចោទនេះ គឺជាអំពើលួចមានស្ថានទម្ងន់ទោស ដែលជាបទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាម ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងមហាអយ្យការដែលសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឃើញថាធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់យោងមាត្រា ៣៧៥ និងមាត្រា ៣៨២ថ្មី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ជនជាប់ចោទបានសារភាព ហើយជនជាប់ចោទប្តឹងឧទ្ធរណ៍នឹងចំណុចទាំងមូលតែពេលនេះបានបង្ហាញឆន្ទៈគ្រាន់តែសុំបន្ធូរបន្ថយទោស តែការដែលសាលាដំបូងសម្រេចផ្តន្ទាទោសនេះឃើញថាស្ថិតនៅក្នុងកម្រិតអប្បបរមាហើយ សូមក្រុមប្រឹក្សាសម្រេចតម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការដដែល។ ក្រុមប្រឹក្សាយល់ឃើញថា ការសន្និដ្ឋាននេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ស្របតាមអង្គហេតុហើយ គប្បីក្រុមប្រឹក្សាសម្រេចតម្កល់ទុកជាបានការដដែល ។

៤-សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទដែលសន្និដ្ឋានថា ក្រោយពីពិភាក្សាដេញដោល ឃើញថាកូនក្តីខ្លួនបានសារភាពថាខ្លួនបានប្រព្រឹត្តដូចការចោទប្រកាន់ដោយឥតលាក់លៀម។ ជាងនេះទៅទៀតកូនក្តីមិនបានកាប់គាស់ទម្លុះទម្លាយទេ គឺកូនក្តីខ្លួនគ្រាន់តែបានរុញបង្អួចរួចក៏ចូលទៅបើកទ្វារពីខាងក្នុងរួចក៏បណ្តើរម៉ូតូចេញ។ សូមក្រុមប្រឹក្សាសម្រេចបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនតាមមាត្រា៩៣ នៃក្រមព្រហ្មទណ្ឌ។

៥-ក្រុមប្រឹក្សាយល់ឃើញថា សាលក្រមព្រហ្មទណ្ឌលេខ ២៩៥ ក្រ៥ "ធ" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុ និងសេចក្តីសម្រេច មកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់រួចហើយ គប្បីក្រុមប្រឹក្សាតម្កល់ទុកសេចក្តីសម្រេចនេះជាបានការបានដដែល ។



Scanned by CamScanner

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ ៥៤៥ ចុះថ្ងៃទី ១៥-០៨-២០១៥ របស់ជនជាប់ចោទឈ្[redacted]ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះមូលដ្ឋានគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៩៥ ក្រ៥ "ធ" ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ ២០១៦ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]ាមនីតិវិធី។

៤-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]និងមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

បើកប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា[redacted] | ហត្ថលេខា [redacted] | ហត្ថលេខ[redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

*រាជធានីភ្នំពេញ* ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner